# របាយការណ៍ស្តីពីវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសមន្ទីរពិសោធន៍ និង ការផ្តល់ប្រឹក្សា សំរាប់ការអង្កេតតាមលក្ខណៈជីវសាស្ត្រ ឥរិយាបថ ការប្រព្រឹត្តផ្លូវភេទ និងការប៉ាន់ប្រមាណរកចំនួនក្រុមអ្នកចាក់ និងអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា ឆ្នាំ២០២៤

**យោង៖** លិខិតបេសកកម្មលេខ៖ ០១៥៧ មជអសកចុះ ថ្ងៃទី២៤ខែឧសភា ឆ្នាំ ២០២៤ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគបានអនុញ្ញាតបេសកកម្មអោយមន្ត្រីចំនួន ០៤នាក់៖

| | | |
|---|---|---|
| - លោកវេជ្ជ. សំរិត សុវណ្ណរិទ្ធ | តួនាទី | អនុប្រធានមជ្ឈមណ្ឌលជាតិ |
| - លោកវេជ្ជ. ង៉ូវ បូរ៉ា | តួនាទី | អនុប្រធានមជ្ឈមណ្ឌលជាតិ |
| - លោកវេជ្ជ. គឹម ប៊ុណ្ណា | តួនាទី | មន្ត្រី |
| - លោក សុខ ចំរើន | តួនាទី | អ្នកបើកបរ |

**យោង៖** លិខិតបេសកកម្មលេខ៖ ១៥៩ មជអសក ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ២០២៤ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគបានអនុញ្ញាតបេសកកម្មអោយមន្ត្រីចំនួន០៨នាក់៖

| | | |
|---|---|---|
| - លោកស្រីវេជ្ជ. ចាន់ ណាវី | តួនាទី | ប្រធាន ផ្នែកអង្កេតតាមដាន |
| - លោកស្រីគ្រូពេទ្យ ណុល ធីតា | តួនាទី | មន្ត្រី |
| - លោកស្រី សេង សុភាតា | តួនាទី | មន្ត្រី |
| - លោក ពៅ សុខណា | តួនាទី | មន្ត្រី |
| - លោកស្រី ជា សុភាព | តួនាទី | មន្ត្រី |
| - លោកស្រី ពេជ្រ បញ្ញា | តួនាទី | មន្ត្រី |
| - លោកស្រី អ៊ឹង ហ្គេចហ្វង | តួនាទី | មន្ត្រី |
| - លោក ម៉ក់ ប៊ុនថន | តួនាទី | អ្នកបើកបរ |

**យោង៖** លិខិតបេសកកម្មលេខ ១៥៨ មជអសក ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០២៤ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគបានអនុញ្ញាតបេសកកម្មអោយមន្ត្រីចំនួន០៨នាក់៖

| | | |
|---|---|---|
| - លោកវេជ្ជ. ឡាយ បញ្ញាវ័ន្ត | តួនាទី | អនុប្រធានផ្នែកអង្កេតតាមដាន |
| - លោកវេជ្ជ. គា ចិត្រា | តួនាទី | មន្ត្រី |
| - លោក ម៉ុម ច័ន្ទតារា | តួនាទី | មន្ត្រី |
| - លោកវេជ្ជ. នុត សុផល | តួនាទី | មន្ត្រី |
| - លោក ឆាយ សុភា | តួនាទី | មន្ត្រី |
| - លោកស្រី សួរ រចនា | តួនាទី | មន្ត្រី |
| - លោកស្រី ហេង វ៉ាន់នី | តួនាទី | មន្ត្រី |
| - លោក ប៊ុន ឃួន | តួនាទី | អ្នកបើកបរ |

**សមាសភាពចូលរួមមាន :**

-មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ ចំនួន ២០នាក់
-អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ចំនួន ០៤នាក់
-អង្គការ FHI (គំរោង Epic) ចំនួន ០១នាក់
-សិក្ខាកាមមកពី៨ខេត្ត-រាជធានី ចំនួន២០នាក់រួមមាន៖

១. រាជធានីភ្នំពេញអ្នកបច្ចេកទេសមន្ទីរពិសោធន៏ចំនួន ០២នាក់ អ្នកផ្តល់ប្រឹក្សាចំនួន ០២នាក់
២. ខេត្តសៀមរាបអ្នកបច្ចេកទេសមន្ទីរពិសោធន៏ចំនួន ០១នាក់ អ្នកផ្តល់ប្រឹក្សាចំនួន ០១នាក់
៣. ខេត្តបាត់ដំបងអ្នកបច្ចេកទេសមន្ទីរពិសោធន៏ចំនួន ០១នាក់ អ្នកផ្តល់ប្រឹក្សាចំនួន ០១នាក់
៤. ខេត្តបន្ទាយមានជ័យ៖
 -ក្រុងសិរីសោភ័ណអ្នកបច្ចេកទេសមន្ទីរពិសោធន៏ចំនួន ០១នាក់ អ្នកផ្តល់ប្រឹក្សាចំនួន ០១នាក់
 -ក្រុងប៉ោយប៉ែតអ្នកបច្ចេកទេសមន្ទីរពិសោធន៏ចំនួន ០១នាក់ អ្នកផ្តល់ប្រឹក្សាចំនួន ០១នាក់
៥. ខេត្តព្រះសីហនុអ្នកបច្ចេកទេសមន្ទីរពិសោធន៏ចំនួន ០១នាក់ អ្នកផ្តល់ប្រឹក្សាចំនួន ០១នាក់
៦. ខេត្តកំពង់ចាមអ្នកបច្ចេកទេសមន្ទីរពិសោធន៏ចំនួន ០១នាក់ អ្នកផ្តល់ប្រឹក្សាចំនួន ០១នាក់
៧. ខេត្តកណ្តាលអ្នកបច្ចេកទេសមន្ទីរពិសោធន៏ចំនួន ០១នាក់ អ្នកផ្តល់ប្រឹក្សាចំនួន ០១នាក់
៨. ខេត្តព្រៃវែងអ្នកបច្ចេកទេសមន្ទីរពិសោធន៏ចំនួន ០១នាក់ អ្នកផ្តល់ប្រឹក្សាចំនួន ០១នាក់

**សរុបអ្នកចូលរួមមានចំនួនៈ ៤៥នាក់**

| | |
|---|---|
| Budget Line និងប្រភពថវិកា | ថវិកាគំរោងមូលនិធិសកល (BL:2.0055) |
| **គោលដៅ និងទីកន្លែង** | ធ្វើការការអង្កេតតាមលក្ខណៈជីវសាស្រ្ត ឥរិយាបថ ការប្រព្រឹត្តផ្លូវភេទ និងការប៉ាន់ប្រមាណរកចំនួនក្រុមអ្នកចាក់ និងអ្នក ប្រើប្រាស់គ្រឿងញៀននៅកម្ពុជា ឆ្នាំ២០២៤ |
| **ពេលវេលា** | ថ្ងៃទី ២៨ដល់ ៣១ខែ ឧសភាឆ្នាំ ២០២៤ |

**សេចក្តីផ្តើម ៖**

រៀបចំបើកវគ្គបណ្តុះបណ្តាលដល់អ្នកបច្ចេកទេសមន្ទីរពិសោធន៏ និង អ្នកផ្តល់ប្រឹក្សា ដើម្បីធ្វើការអង្កេតតាមលក្ខណៈជីវសាស្រ្ត ឥរិយាបថ ការប្រព្រឹត្តផ្លូវភេទ និងការប៉ាន់ប្រមាណរកចំនួនក្រុមអ្នកចាក់ និងអ្នក ប្រើប្រាស់គ្រឿងញៀន នៅកម្ពុជា ឆ្នាំ២០២៤ ។

❖ **គោលបំណង ៖**

- ✓ ផ្តល់ចំណេះដឹងស្តីពីមូលដ្ឋានគ្រឹះនៃមេរោគអេដស៍និងជំងឺអេដស៍
- ✓ ផ្តល់ព័ត៌មានស្តីពីក្រមសីលធម៍និងច្បាប់អេដស៍(តួនាទីមន្រ្តីបច្ចេកទេសមន្ទីរពិសោធន៏ និង អ្នកផ្តល់ប្រឹក្សា)
- ✓ ផ្តល់ព័ត៌មានស្តីពីទំនាក់ទំនងរវាងសេវាធ្វើតេស្តឈាមរកមេរោគអេដស៍និងសេវាព្យាបាលជំងឺអេដស៍
- ✓ ផ្តល់ចំណេះដឹងពី បច្ចេកទេសមន្ទីរពិសោធន៏ និង បច្ចេកទេសផ្តល់ប្រឹក្សា សំរាប់ធ្វើការអង្កេតលើក្រុមអ្នកចាក់ និង អ្នកប្រើប្រាស់គ្រឿងញៀន។
- ✓ ត្រៀមខ្លួនចូលរួមក្នុងការប្រមូលទិន្នន័យសំរាប់ការអង្កេតលើការប្រព្រឹត្តិប្រចាំឆ្នាំ២០២៤ ដោយធ្វើការសិក្សាលើបញ្ហាដែលធ្លាប់កើតមានឡើងក្នុងការអង្កេតកន្លងមក ។

❖ **លទ្ធផលនៃសកម្មភាពដែលបានអនុវត្តន៏ ៖**

## ថ្ងៃទី ២៨ខែ ឧសភា ឆ្នាំ២០២៤

វគ្គបណ្តុះបណ្តាលបានចាប់ផ្តើមនៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០២៤ វេលាម៉ោង៨:៣០ព្រឹកលោកវេជ្ជបណ្ឌិត សំរិត សុវណ្ណារិទ្ធ អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ មានចំណាប់អារម្មណ៍ និងអនុសាសន៍ទាក់ទងនឹង:

- លើកឡើងពីលទ្ធផលនៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍/កាមរោគ ក្នុងការសិក្សាស្រាវជ្រាវនាឆ្នាំកន្លងមក ដើម្បីអោយសិក្ខាកាមបានដឹង និងខិតខំប្រឹងប្រែងក្នុងការងារអង្កេតនេះ អោយបានលទ្ធផលល្អ និងមានគុណភាពល្អ
- គោលបំណងសំខាន់ក្នុងការកាត់បន្ថយអត្រាប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍អោយចុះមក 0% នៅឆ្នាំ២០២៥។
- សិក្ខាកាមត្រូវបង្កើនការយល់ដឹង និងយកចិត្តទុកដាក់លើការងារបច្ចេកទេសដើម្បីការអង្កេតស្រាវជ្រាវបានដំណើរការទៅដោយរលូនប្រកបដោយគុណភាព។
- កំហុសដែលធ្លាប់បានជួបប្រទះញឹកញាប់នៅពេលចុះប្រមូលទិន្នន័យកន្លងមក ផ្នែកអង្កេតតាមដាន របស់មជ្ឈមណ្ឌលជាតិ ត្រូវធានាថាត្រូវបានកែប្រែ ដើម្បីអោយការការងារអង្កេតស្រាវជ្រាវសំរាប់ឆ្នាំ២០២៤នេះទទួលបានលទ្ធផលកាន់តែប្រសើរជាងឆ្នាំមុន។

លោកអនុប្រធានមជ្ឈមណ្ឌលជាតិបានសំណេះសំណាលជាមួយសិក្ខាកាមអោយមានការខិតខំយកចិត្តទុកដាក់ក្នុងវគ្គបណ្តុះបណ្តាលអោយបានល្អ សំរាប់យកទៅប្រើប្រាស់ក្នុងពេលចុះប្រមូលទិន្នន័យខាងមុខ ដើម្បីអោយការអង្កេតស្រាវជ្រាវដំណើរការបានដោយរលូនប្រកបដោយគុណភាព និងទទួលបានជោគជ័យ និងលោកអនុប្រធានបានប្រកាសបើកវគ្គបណ្តុះបណ្តាល។

ជាបន្ទាប់មានការបង្ហាញអំពី៖

⇒ លោកបណ្ឌិត គា ចិត្រា បានបង្ហាញពីលទ្ធផលការអង្កេតរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ កាមរោគ ក្នុងចំណោមអ្នកចាក់ និងអ្នកប្រើគ្រឿងញៀនឆ្នាំ២០១៧ដល់សិក្ខាកាមដើម្បីជ្រាបពីលទ្ធផលការងារបានធ្វើនាឆ្នាំកន្លងមក។

⇒ លោកស្រីវេជ្ជបណ្ឌិត ចាន់ ណារី បង្ហាញពីពិធីសារនៃការងារអង្កេតរកអត្រាផ្ទុកមេរោគអេដស៍កាមរោគការប្រព្រឹត្តផ្លូវភេទ និងការប៉ាន់ស្មានរកចំនួនក្នុងចំណោមអ្នកចាក់ និងអ្នកប្រើគ្រឿងញៀនឆ្នាំ២០២៤។

⇒ លោកបណ្ឌិត គា ចិត្រា បានបង្ហាញពីគោលការណ៍ណែនាំសំរាប់ការងារអង្កេតរកអត្រាផ្ទុកមេរោគអេដស៍កាមរោគការប្រព្រឹត្តប្រឈមមុខនឹងគ្រោះថ្នាក់។

⇒ លោក ពៅ សុខណា បានបង្ហាញពី របៀបនៃការផ្តល់ប្រឹក្សា និង ការសុំការយល់ព្រម និង របៀបបំពេញលើឯកសាររបស់អ្នកផ្តល់ប្រឹក្សា។

⇒ លោក ពៅ សុខណា បានបង្ហាញពី វិធីសាស្រ្ត និង ការយកឈាមម្តងទៀតនៅពេលមានវិជ្ជមានរោគស្វាយ។

## ថ្ងៃទី២៩ខែ ឧសភា ឆ្នាំ២០២៤

⇒ មន្រ្តីផ្នែកអង្កេតតាមដាន និង មន្រ្តីផ្នែកក្រុមEpic (FHI360) បង្ហាញពី របៀបបញ្ចូលលទ្ធផលតាមប្រព័ន្ធអេឡិចត្រូនិច។

⇒ មន្រ្តីផ្នែកអង្កេតតាមដាន និងមន្រ្តីផ្នែកក្រុម Epic (FHI360)សាកល្បងបញ្ចូលលទ្ធផលតាមប្រពន្ធ័អេឡិចត្រូនិករួចផ្ញើរទៅ Sever

⇒ លោក ម៉ុម ចន្ទ័តារា បង្ហាញពីបច្ចេកទេសមន្ទីរពិសោធន៍ Safety and Hygiene for working with biological product ។

⇒ លោកស្រី ពេជ្រ បញ្ញា បង្ហាញពីបច្ចេកទេសមន្ទីរពិសោធន៍ Sample collection for IBBS survey (CT/NG, HIV and Syphilis) ។

## ថ្ងៃទី៣០ខែ ឧសភា ឆ្នាំ២០២៤

- ⇒ លោក ម៉ុម ចន្ទ័តារា បង្ហាញពីបច្ចេកទេសមន្ទីរពិសោធន៍ Safety and Hygiene for working with biological product
- ⇒ លោកស្រី ពេជ្រ បញ្ញា និងលោក យុន កក្កដា បង្ហាញពីបច្ចេកទេសមន្ទីរពិសោធន៍ Sample collection for IBBS survey (CT/NG, HIV and Syphilis)
- ⇒ លោកស្រី ពេជ្រ បញ្ញា និងលោក យុន កក្កដា បង្ហាញពីបច្ចេកទេសមន្ទីរពិសោធន៍ Urethral swab use multi-Collection swab (Abbott swab)
- ⇒ លោក ម៉ុម ចន្ទ័តារា បង្ហាញពីបច្ចេកទេសមន្ទីរពិសោធន៍ Specimen storage and transport laboratory for testing

## ថ្ងៃទី៣១ខែ ឧសភា ឆ្នាំ២០២៤

- ⇒ លោក ម៉ុម ចន្ទ័តារា បង្ហាញពីបច្ចេកទេសមន្ទីរពិសោធន៍ Demonstration and practice for sample collection.
- ⇒ លោកវេជ្ជ. ឡាយ បញ្ញាវន្ត បង្ហាញពីរបៀបប្រើប្រាស់ ការបំពេញឯកសារផ្សេងៗ សំរាប់បំរើអោយ ការងារប្រមូលទិន្នន័យ និងការបំពេញលើបណ្ណ័គូប៉ុង បន្ទាប់ពីបញ្ចប់ការងារ។

ក្រោយពីការបង្ហាញចប់វគ្គបណ្តុះបណ្តាលតំរូវអោយសិក្ខាកាមទាំងអស់ សាកល្បងការងារជាក់ស្តែងទៅលើការធ្វើតេស្ត សាលល្បងធ្វើការផ្តល់ប្រឹក្សា មុន និង ក្រោយធ្វើតេស្តឈាម និង សាកល្បងបញ្ចូលលទ្ធផលតាមប្រពន្ធ័អេឡិចត្រូនិក (Tablet)។

## ❖ បញ្ហាដែលបានជួបប្រទះ និងដំណោះស្រាយ

នៅក្នុងចំណោមមន្ត្រីដែលមកពី៨ខេត្ត-រាជធានី មានខេត្តខ្លះដែលពួកគាត់មិនច្បាស់ថា ដល់ថ្ងៃដែលត្រូវធ្វើការអង្កេតជាក់ស្តែង ពួកគាត់នឹងត្រូវបានចូលរួមធ្វើការអង្កេតជាមួយក្រុមអង្កេតរបស់ថ្នាក់ជាតិដែរឬទេ? ពីព្រោះអាចកន្លែង ការងារ មានការផ្លាស់ប្តូរសមាសភាពពួកគាត់ ដែលកន្លងមកក្រុមការងាររបស់ផ្នែកអង្កេតតាមដាន តែងជួបបញ្ហានេះ ជារឿង រហូតមក។

ជាដំណោះស្រាយក្រុមការងារតែងសំនូមពរអោយខាងកម្មវិធីអេដស៍ខេត្តជួយសម្របសម្រួលបញ្ហាដែលកើតឡើង ក៏ប៉ុន្តែខេត្តខ្លះនៅតែសម្របសម្រួលមិនបានជោគជ័យ អញ្ចឹងខាងក្រុមការងារមានតែអនុវត្តន៏ទៅតាមអ្វីដែលគេផ្តល់អោយ។

## ❖ សំណូមពរ ឬអនុសាសន៍

សិក្ខាកាមសុំអោយមានការសហការគ្នាល្អ ពេលដែលមានអតិថិជនស្នាក់ស្នើចិត្ត ដើម្បីអោយអតិថិជនមានអារម្មណ៍កក់ក្តៅក្នុងការសំរេចចិត្តចូលរួម។

ក្រុមការងារបានសំណូមពរដល់សិក្ខាកាមអោយស្លៀកពាក់ឯកសណ្ឋានតាមស្ថាប័នរៀងខ្លួនពេលចុះប្រមូលទិន្នន័យក្នុងការអង្កេតស្រាវជ្រាវ។

សិក្ខាកាមសុំអោយក្រុមការងារថ្នាក់ជាតិជួយសំរបសំរួលបញ្ហាសមត្ថកិច្ចកុំអោយមានការចាប់ អតិថិជនមានការភ័យខ្លាចពេលធ្វើដំណើរមកចូលរួម។

វគ្គបណ្តុះបណ្តាលបានបញ្ចប់នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២៤ វេលាម៉ោង ៤:៣០ល្ងាច ដោយមានការពិភាក្សាទូទៅ និងផ្តល់អនុសាសន៍ដោយលោកវេជ្ជបណ្ឌិតសំរិត សុវណ្ណរិទ្ធ អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើ

សិក្ខាកាមសុំអោយក្រុមការងារថ្នាក់ជាតិជួយសំរបសំរួលបញ្ហាសមត្ថកិច្ចកុំអោយមានការចាប់ អតិថិជនមានការភ័យខ្លាចពេលធ្វើដំណើរមកចូលរួម។

វគ្គបណ្តុះបណ្តាលបានបញ្ចប់នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២៤ វេលាម៉ោង ៤:៣០ល្ងាច ដោយមានការពិភាក្សាទូទៅ និងផ្តល់អនុសាសន៍ដោយលោកវេជ្ជបណ្ឌិតសំរិត សុវណ្ណរិទ្ធ អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានផ្តល់ការណែនាំពី ការងារបច្ចេកទេសជំនាញ ព្រមទាំងបានឆ្លើយតបទៅនឹងសំណួមតរ និងបានសំណេះសំណាលផ្តាំផ្ញើដល់សិក្ខាកាមអោយមានការទទួលខុសត្រូវខ្ពស់ក្នុងការងាររបស់ខ្លួនពេលចុះប្រមូលទិន្នន័យខាងមុខ ដើម្បីអោយការអង្កេស្រាវជ្រាវ ដំណើរការបានដោយរលូន ប្រកបដោយគុណភាព និងទទួលបានជោគជ័យ រួចហើយលោកអនុប្រធានមជ្ឈមណ្ឌលជាតិបានប្រកាសបិទវគ្គបណ្តុះបណ្តាល។

## ❖ សេចក្តីសន្និដ្ឋាន និងផែនការបន្ទាប់

ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាលសិក្ខាកាមទទួលបានៈ

យល់ច្បាស់ពី តួនាទី ភារកិច្ច និងការទទួលខុស ចំពោះការធ្វើតេស្តឈាម និងការផ្តល់ប្រឹក្សាព្រមទាំងយកសំណាក(Swab)

សិក្ខាកាមបានត្រៀមលក្ខណៈចូលរួមក្នុងការប្រមូលទិន្នន័យសំរាប់ការអង្កេតស្រាវជ្រាវលើ ក្រុមអ្នកចាក់ និងអ្នកប្រើគ្រឿងញៀនឆ្នាំ២០២៤

បានកែលំអរលើបញ្ហាដែលធ្លាប់កើតមានឡើងក្នុងការអង្កេតស្រាវជ្រាវកន្លងមក

វគ្គបណ្តុះបណ្តាលទាំងមូលបានបញ្ចប់ដោយភាពជោគជ័យ ហើយមន្ត្រីដែលចូលរួមទាំងអស់នឹងអាចធ្វើការអង្កេតតាមលក្ខណៈជីវសាស្ត្រ ឥរិយាបថ ការប្រព្រឹត្តផ្លូវភេទ និងការប៉ាន់ប្រមាណរកចំនួនក្រុមអ្នកចាក់ និងអ្នក ប្រើប្រាស់គ្រឿងញៀននៅកម្ពុជា ឆ្នាំ២០២៤ ដោយរលូន។

ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០២៤

អ្នកធ្វើរបាយការណ៍

លោកស្រី សេង សុភាតា

បានឃើញ និងឯកភាព

**ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ អេដស៍ សើស្បែក និងកាមរោគ**

**អនុប្រធាន**

**វេជ្ជ.សំរិត សុវណ្ណរិទ្ធ**